**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ:២៦១
ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០២
<u>សាលដីកា</u>
លេខ:២៣
ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម **ឌិត មុន្នី** ជាប្រធាន
២-លោក **ស៊ិន ឌឹម** ជាចៅក្រម
៣-លោក **ជីវ កេង** ជាចៅក្រមរបាយការណ៍
៤-លោក **សោម សិរីវឌ្ឍ** ជាចៅក្រម
៥-លោក **ឈឹម ស៊ីផល** ជាចៅក្រម
៦-លោក **ប្រាក់ គឹមសាន** ជាចៅក្រម
៧-លោក **យស់ សូខឿន** ជាចៅក្រម
៨-លោក **ប៉ែន សារឿន** ជាចៅក្រម
៩-លោក **ម៉ុង មុន្នីចរិយា** ជាចៅក្រម

<u>ក្រឡាបញ្ជី</u>

-លោកស្រី **ភួង ចន្ថា**

<u>តំណាងមហាអយ្យការ</u>

-លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ៧៨(ង) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០២ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ២២ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះជា ពៅ (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើពេទ្យ មានទីលំនៅនៅ ភូមិ១៣មករា ឃុំព្រែកព្រះស្តេច ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

និងចុងចម្លើយឈ្មោះមាន ទូច (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ២៦ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ មានទីលំនៅនៅផ្ទះលេខ៤៥៨$CE_0$ ផ្លូវ១៦៣ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមនក្រុងភ្នំពេញ ។

- លោក ប៉ិច វិច្ឆិកា ជាមេធាវីការពារឲ្យចុងចម្លើយ អ្នកស្រី មាន ទូច

<u>កម្មវត្ថុបណ្តឹង:</u> **ប្តឹងសុំផ្តាច់សមគ្គសង្វាស ។**

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ២៦៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០២ របស់មេធាវី លោកប៉ិច វិច្ឆិកា ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ៧៨(ង) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍លើចំណុចសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៦១ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០២ របស់តុលាការ កំពូល។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០០ របស់លោក ជា ពៅ ជាដើមចោទ ប្តឹងសុំផ្តាច់ សមគ្គសង្វាសពីអ្នកស្រីមាន ទូច ហៅលឹម ហ៊ុយឃីម ជាប្រពន្ធដោយសំអាងហេតុថា ប្រពន្ធជាមនុស្ស គ្មានអធ្យាស្រ័យក្នុងគ្រួសារ ធ្វើអ្វីតាមតែទំនើងចិត្តខ្លួនឯង គ្មានការពិគ្រោះពិចារណាជាមួយខ្លួនជាប្តីសោះ ពេលខឹងចុះចេញពីផ្ទះដោយគ្មានប្រាប់ខ្លួនមួយម៉ាត់សោះទោះបីខ្លួនតាមហៅឲ្យមកផ្ទះវិញក៏មិនព្រមដែរ។

បានឃើញសាលក្រមលេខ២៧៥ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០០ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេច ដូចតទៅ ។

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០០ របស់ឈ្មោះជា ពៅ ជាដើមចោទប្តឹងសុំ ផ្តាច់សមគ្គសង្វាសពីឈ្មោះនាងមាន ទូច ហៅលឹម ហ៊ុយឃីម ជាប្រពន្ធទុកជាត្រឹមត្រូវតាមទម្រង់ និងគតិ ច្បាប់ ។

២- ឲ្យឈ្មោះជា ពៅ និង នាងមាន ទូច ដាច់សមគ្គសង្វាសពីគ្នាចាប់ពីថ្ងៃដែលសាលក្រមនេះចូល ជាស្ថាពរ ។

៣- ឲ្យឈ្មោះនាងមាន ទូច ហៅលឹម ហ៊ុយឃីម ស្ថិតក្នុងភាពមេម៉ាយចំនួន៣០០ថ្ងៃ គិតចាប់ពីថ្ងៃ ប្រកាសសាលក្រមនេះតទៅ ។

៤- កូនមួយនាក់ឈ្មោះជា សុខអេង ភេទស្រីអាយុ ២ឆ្នាំ ប្រគល់ឲ្យឈ្មោះនាងមាន ទូច ហៅលឹម ហ៊ុយឃីម ជាម្តាយចិញ្ចឹមបីបាច់ថែរក្សា តែឲ្យឈ្មោះជា ពៅ ជាឪពុកចេញប្រាក់ ឧបត្ថម្ភរយៈពេលពីរឆ្នាំ ដែលឈ្មោះនេះពុំបានជួយចិញ្ចឹមកូនជាប្រាក់ចំនួន៥០០.០០០រៀល (ប្រាំរយពាន់រៀល) និងជួយចេញ ប្រាក់អាហារកិច្ចចិញ្ចឹមកូនមួយនាក់នេះ ក្នុងមួយខែចំនួន៣០.០០០រៀល រាប់ខែចាប់ពីដំណាច់ ខែមករា ឆ្នាំ២០០១ នេះតទៅរហូតដល់កូនមាននីតិភាព ។

៥- ទុកសិទ្ធិឲ្យឈ្មោះជា ពៅ ជាឪពុក ទៅសួរសុខទុក្ខកូនបាន ។

តាមមាត្រា៩. ៣៩. ៥៥. ៥៩. ៧២.៧៣.៧៤.និង៧៥ នៃច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ៥៦ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ។

៦- ទ្រព្យសម្បត្តិដើមចោទរបស់ឈ្មោះនាង មាន ទូច ហៅលឹម ហ៊ុយឃីម មានម៉ូតូចាលីពណ៌ ក្រហមធុន៥០មួយគ្រឿង បន្តោងផ្លាទីនរូបបេះដូងដាក់រូបថតការមួយ ចិញ្ចៀនផ្លាទីនដាំត្បូងក្រហម លាយសមួយវង់ , ក្រវិលផ្លាទីនមួយសំរាប់ និងសំលៀកបំពាក់មួយកាបូប ដែលស្ថិតក្រោមការគ្រប់គ្រង

របស់ឈ្មោះជា ពៅ ជាដើមចោទ ត្រូវប្រគល់ឲ្យទៅឈ្មោះនាងមាន ទូច វិញ ចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។

៧- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧.០០០រៀល ដែលដើមចោទបានបង់រួចហើយគឺ :

- ពន្ធចុះបញ្ជី និង ពន្ធហ៊្នឹង ១.៨០០រៀល

- រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល

- ចំណាយក្នុងកិច្ចស៊ើបសួរ : ៥.០០០រៀល

សរុប ៧.០០០រៀល

តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៧ក្រចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ ១៩៩៣ ។

៨- សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទកំបាំងមុខចុងចម្លើយ ។

ទុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ២៥ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០០ របស់អ្នកស្រីមាន ទូច ប្តឹងមិនសុខចិត្ត នឹងសាលក្រមកំបាំងមុខលេខ២៧៥ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០០ របស់តុលាការខេត្តបាត់ដំបងត្រង់ចំណុចទី៤ និង៦ នៃសេចក្តីសម្រេច ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ០១(ខ)ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០១ របស់តុលាការខេត្ត បាត់ដំបង ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅះ

១-ក.ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០០ លើចំណុចទី៤ និងចំណុចទី៦ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

ខ.ទទួលយកលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ របស់នាងមាន ទូច ហៅលីម ហ៊ុយឃីម ជាចុងចម្លើយ ឲ្យទៅលោកវ៉ាយ ប៊ុនធឿន ដំណើរការរឿងក្តី ទុកជាត្រឹមត្រូវតាម ច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២៧៥ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០០ របស់តុលាការ ខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល លើកលែងតែចំណុចទី៤ និង ទី៦ ធ្វើការកែប្រែដូចខាងក្រោមះ ក.ចំណុចទី៤ គឺ : កូនមួយនាក់ឈ្មោះជា សុខអេង ភេទស្រីអាយុ ២ឆ្នាំ ប្រគល់ ឲ្យឈ្មោះនាងមាន ទូច ជាម្តាយចិញ្ចឹមបីបាច់ថែរក្សាតែឲ្យឈ្មោះជា ពៅ ជាឪពុកចេញប្រាក់ឧបត្ថម្ភរយៈពេលពីរឆ្នាំ ដែលឈ្មោះនេះពុំបានជួយចិញ្ចឹមកូនជាប្រាក់ចំនួន ១.០០០.០០០រៀល (មួយលានរៀល) និងជួយចេញប្រាក់អាហារកិច្ចចិញ្ចឹមកូនក្នុងមួយខែចំនួន៤០.០០០រៀល រៀងរាល់ខែ រហូតដល់កូនមាននីតិភាពគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។ ចុងចម្លើយទាមទារលើសពីនេះបដិសេធចោល ។

ខ.ចំណុចទី៦ គឺ : ទ្រព្យសម្បត្តិដើមរបស់ឈ្មោះនាងមាន ទូច ហៅលីម ហ៊ុយឃីមមានម៉ូតូឆាលីធុន៥០មួយគ្រឿង បន្តោងផ្លាទីនរូបបេះដូងដាក់រូបថតការ ចិញ្ចៀនផ្លាមីនមួយវង់ ដាំត្បូង ក្រហមលាយ

ស គ្រវិលផ្លាទីនមួយសំរាប់ សំលៀកបំពាក់មួយកាបូប សំលៀកបំពាក់កូនមួយកាបូប នាឡិកា ដៃស្រីមួយគ្រឿង និង កង្ហារបក់មួយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះដា ពៅ ជាដើមចោទត្រូវប្រគល់ឲ្យឈ្មោះនាងមាន ទូច វិញចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។

-ទ្រព្យសម្បត្តិរួមគឺ មានចិញ្ចៀនចំរៀកផ្កា៣វង់ ធ្វើពីមាសប្រគល់ឲ្យឈ្មោះនាងមាន ទូច ហៅលីម ហ៊ុយឃីម ជាកម្មសិទ្ធិចំនួនពាក់កណ្តាល និងពាក់កណ្តាលទៀតប្រគល់ឲ្យជាទ្រព្យរបស់កូនឈ្មោះ ដា សុខអេង គិតចាប់ពីថ្ងៃដែលសាលក្រមនេះ ចូលជាស្ថាពរ ។

តាមមាត្រា៦២ និង ៦៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ៥៦ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ។

៣-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទកំបាំងមុខ ចុងចម្លើយតែទុកដូចចំពោះមុខ ។

បើកផ្លូវប្តឹងឧទ្ធរណ៍ពីរខែ គិតពីថ្ងៃកាត់ក្តី ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣៤ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ របស់ក៉ាយ ប៊ុនធឿន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ០១(ខ) ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០១ របស់តុលាការខេត្តបាត់ដំបងលើចំណុចទី២(ក) និងទី២(ខ) ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣៩(ច) ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ៖

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ របស់មេធាវី ក៉ាយ ប៊ុនធឿន ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធចំណុចទី២ នៃសេចក្តីសម្រេចរបស់សាលក្រមរដ្ឋប្បវេណីលេខ០១(ខ) ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០១ របស់តុលាការខេត្តបាត់ដំបងចោលជាអសារបង់ ។ ចំណុចក្រៅពីនេះរក្សា ទុកជាបានការដដែល ។

៣- បង្គាប់ឲ្យដើមចោទឈ្មោះដា ពៅ បង់ប្រាក់អាហារកិច្ចផ្តាច់ឲ្យទៅចុងចម្លើយឈ្មោះ មាន ទូច ហៅលីម ហ៊ុយឃីមចំនួន៩.០០០.០០០រៀល (ប្រាំបួនលានរៀល) ។ សំណូមពរលើស ពីនេះបដិសេធចោល ។

៤- កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលឈ្មោះដា ពៅ បានបង់ទុករួចហើយគឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល និងលើអាជ្ញាធរតុលាការ៥.០០០រៀល សរុប ១៣.០០០ រៀលបង្គាប់ឲ្យឈ្មោះ មាន ទូច ហៅលីម ហ៊ុយឃីម សងប្រាក់១៣.០០០រៀល ទៅឈ្មោះដា ពៅ វិញនៅពេលសាលដីកាចូលជាស្ថាពរ ។

៥- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និង មេធាវីតំណាងរបស់ចុងចម្លើយ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៤៧ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០០១ របស់អ្នកស្រីមាន ទូច ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៣៩(ច) ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចទី៣ និង ទី៤ ស្តីពីអាហារកិច្ច និង ទ្រព្យសម្បត្តិរួម ។

បានឃើញសាលដីកាលេខ៤៦ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០២ របស់តុលាការកំពូលដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ៖

១- ទទួលបណ្តឹងសាទុក្ខលេខ២៤៧ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០១ របស់អ្នកស្រីមាន ទូច ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៣៩(ច) ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២៤៧ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកជា ពៅ បានបង់ជួសរួចហើយគឺ៖

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០២ ។

បានឃើញដីកាបញ្ជូនលេខ១០៣/០២ សរណ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍វិញ ដើម្បីចាត់ការតាមច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៨(ង) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ៖

១- ទទួលជំនុំជំរះ សំណុំរឿងក្តីរដ្ឋប្បវេណីលេខ២២ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ តាមអំណាចសាលដីការដ្ឋប្បវេណី របស់តុលាការកំពូលលេខ៤៦ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ ២០០២ ។

២- ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០០ របស់ឈ្មោះជា ពៅ សុំផ្តាច់សមគ្គសង្វាស ពីប្រពន្ធឈ្មោះមាន ទូច ហៅលីម ហ៊ុយឃីម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។ តាមមាត្រា១៤ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

៣- កូនមួយនាក់ឈ្មោះជា សុខអេង ភេទស្រី អាយុ ២ឆ្នាំ ត្រូវប្រគល់ឲ្យឈ្មោះមាន ទូច ជាម្តាយចិញ្ចឹមគ្រប់គ្រងបីបាច់ថែរក្សាតទៅ ។

៤- បង្គាប់ឲ្យឈ្មោះជា ពៅ ចេញប្រាក់អាហារកិច្ចចិញ្ចឹមកូនជាប្រាក់ចំនួន៥០.០០០រៀល (ប្រាំម៉ឺនរៀល) ក្នុងមួយខែទៅឲ្យឈ្មោះមាន ទូច ចាប់គិតពីថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៨ រៀងរាល់ខែរហូតដល់កូនមាននីតិភាព ។ សំណូមពរលើសពីនេះ បដិសេធចោល ។

៥- ទុកសិទ្ធិឲ្យឈ្មោះជា ពៅ ទៅសួរសុខទុក្ខកូន ។ តាមមាត្រា៧៣-៧៤ និង៧៥ ច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

៦-ក. ទ្រព្យសម្បត្តិដើមរបស់ឈ្មោះមាន ទូច រួមមានម៉ូតូជាលើពណ៌ក្រហមធុន៥០ មួយគ្រឿង បន្ទោងផ្លាទីតរូបបេះដូងដាក់រូបថតការមួយ ចិញ្ចៀនផ្លាទីនជាំត្បូងក្រហមលាយស១វង់ ក្រវិលផ្លាទីន មួយសំរាប់ និង សំលៀកបំពាក់មួយកាបូប នាឡិកាដៃស្ត្រីមួយគ្រឿង កង្ហាបក់១គ្រឿង ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះជា ពៅ ត្រូវប្រគល់ទៅឲ្យឈ្មោះមាន ទូច វិញនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

ខ. ទ្រព្យសម្បត្តិរួមគឺ ចិញ្ចៀនជំរៀកផ្កា៣វង់ធ្វើអំពីមាស ត្រូវប្រគល់ឲ្យចុងចម្លើយឈ្មោះមាន ទូច តាមសំណូមពររបស់ដើមចោទឈ្មោះជា ពៅ នៅពេលដែលសាលដីកានេះចូលជាស្ថាពរ។

៧- សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខដើមចោទកំបាំងមុខចុង ចម្លើយ ។

បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ២៦៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០២ របស់មេធាវីលោកប៊ិច វិច្ឆិកា ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាឆ្លើយតប ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០២ របស់លោកជា ពៅ ។

បានឃើញសារណាការពារ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០២ របស់លោក ប៊ិច វិច្ឆិកា ជាមេធាវី និងតំណាងផ្ទេរសិទ្ធិឲ្យឈ្មោះ មាន ទូច ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖

-បណ្តឹងសាទុក្ខរបស់មេធាវីការពារឲ្យចុងចម្លើយស្ថិតក្នុងកំណត់ច្បាប់គប្បីលើកយកមក ពិនិត្យពិចារណា ។

- សាលដីការដ្ឋប្បវេណីលេខ៧៨(ង)ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ប៉ុន្តែគួរពិចារណាសម្រេចបន្ថែមអំពីបញ្ហាប្រាក់អាហារកិច្ចចិញ្ចឹមកូន ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះដា ពៅ ជាដើមចោទ និងជាចុងបណ្តឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយថា ខ្លួន និងភរិយាពិតជាបានរៀបការត្រឹមត្រូវតាមច្បាប់ ប៉ុន្តែអត់បានចុះចិត្តសន្យាទេ ។ ចំពោះទ្រព្យសម្បត្តិខ្លួនបានប្រគល់ឲ្យប្រពន្ធខ្លួន រួចអស់ហើយ ។ ការរស់នៅជាមួយគ្នាបានរយៈពេល១ឆ្នាំទេ តាំងពីពេលនោះមកបែកលំនៅគ្នារហូត ។ ខ្លួនមិនបានបើកឃ្លីនិចធំអ្វីទេ គឺគ្រាន់តែបើកមើលជម្ងឺតិចតួចប៉ុណ្ណោះ ព្រោះខ្លួនទើបតែចេញពីសាលាថ្មីៗ នៅឡើយ ។ អត់មានគ្រឿងបរិក្ខាពេទ្យទេ មានតែថ្នាំពេទ្យ និង ម្ហូលសាវាំងប៉ុណ្ណោះ ពីព្រោះខ្លួនរស់នៅជាមួយឪពុកម្តាយ នៅពេលរៀបការហើយ ។ ចំពោះប្រាក់ ២០ម៉ឺនបាតដែលចុងចម្លើយអះអាងថាមាននៅលើខ្លួននោះ គឺខ្លួនសុំបដិសេធចោលទាំងស្រុង ។ ចំណែកប្រាក់អាហារកិច្ចចិញ្ចឹមកូន ខ្លួនឯកភាពបង់ផ្តាច់ក្នុង១ខែ៥០.០០០រៀល ។

បានស្តាប់ចម្លើយរបស់មេធាវី ចុងចម្លើយជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជំរះបានលើកឡើងបញ្ជាក់ថា : នៅក្នុងរឿងក្តីនេះគូភាគី បានរៀបការត្រឹមត្រូវតាមច្បាប់ ។ ការរួមរស់នៅជាមួយគ្នារយៈពេលបីឆ្នាំ បានកូនស្រីម្នាក់អាយុ២ឆ្នាំហើយ ។ ក្នុងរឿងនេះកូនក្តីខ្លួនសុំឲ្យដើមចោទបង់អាហារកិច្ចផ្តាច់ចំនួន ១០.០០០ដុល្លាអាមេរិក សំអាងកូនកើតមកមិនគ្រប់ខែ រវល់តែឈឺរហូតគ្មានប្រាក់សម្រាប់ទិញថ្នាំព្យាបាលកូន ។ ចំណែកប្រាក់២០ ម៉ឺនបាតដែលដើមចោទគ្រប់គ្រងនោះសុំឲ្យតុលាការកំពូលមេត្តាពិចារណា លើប្រាក់នេះផង ព្រោះវាជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធទាំងពីរនាក់ សាលាឧទ្ធរណ៍មិនបានសម្រេចអំពីទ្រព្យសម្បត្តិនេះឡើយ ដូចជាគ្រឿងបរិក្ខា ស្ថិតនៅក្នុងភាពអាថ៌កំបាំង ។

សំណូមពរសុំឱ្យ តុលាការកំពូល មេត្តាសម្រេចចាត់របៀបរឿងក្តីជាថ្មីឡើងវិញ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមចោទ និង សេចក្តីសន្និដ្ឋានការពារ របស់មេធាវីចុងចម្លើយ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២ លេខ២៦៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០២ របស់លោកប៉ិច វិច្ឆិកា មេធាវីរបស់អ្នកស្រី មាន ទូច ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងតាមមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា ការដែលអ្នកស្រីមាន ទូច លើករឿងក្នុងសារណារបស់អ្នកស្រីថា ទ្រព្យសម្បត្តិ រួមដែលមានហើយតុលាការមិនបានយកមកបែងចែក គឺប្រាក់បាតថៃចំនួនពីរសែនបាត និងសំភារៈបរិក្ខាពេទ្យ ប្រហែល២សែនបាតទៀតនោះ គឺពុំមានភស្តុតាងអាចឱ្យតុលាការកំពូលពិចារណាបានឡើយ ។

- យល់ឃើញថា ការណ៍ដែលអ្នកស្រីមាន ទូច លើករឿងក្នុងសារណាចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០០២ របស់អ្នកស្រីថា អ្នកស្រីសុំបើកប្រាក់អាហារកិច្ចចិញ្ចឹមកូន មួយម៉ឺនដុល្លាអាមេរិក ផ្ដាច់តែម្ដង ពីព្រោះ កូនអ្នកស្រីកើតមិនគ្រប់ខែសុខភាពទន់ខ្សោយ ហើយអ្នកស្រីពិបាកធ្វើដំណើរទៅបើកប្រាក់នោះ តុលាការកំពូល ពុំអាចពិចារណាបានឡើយពីព្រោះលោកជា ពៅ ជាមន្ត្រីរាជការដែលមានរបបប្រាក់បៀវត្សកំណត់ច្បាស់លាស់ ប៉ុន្តែនាពេលសវនាការនេះ ដើមចោទយល់ព្រមបង់ប្រាក់អាហារកិច្ចផ្ដាច់តែម្ដង ដោយគិតលើមូលដ្ឋាន ៥០.០០០រៀលក្នុងមួយខែ ។ ដូច្នេះតុលាការកំពូលគប្បីពិចារណាតាមលទ្ធភាព និងតាមសភាពជាក់ស្ដែង ។

- យល់ឃើញថា ការណ៍ដែលសាលាឧទ្ធរណ៍មិនលើកយកចំណងអាពាហ៍ពិពាហ៍មកសម្រេចសេចក្ដីនោះជាការត្រឹមត្រូវហើយ ពីព្រោះគូភាគី ពុំបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តាមមាត្រា១៤ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារទេ ។

- យល់ឃើញថា អ្នកស្រី មាន ទូច ពុំបានមកចូលរួមនាសវនាការនេះទេ ប៉ុន្តែមេធាវីរបស់អ្នកស្រីបានមកចូលរួមហើយ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៧៨(ង) នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ លើក លែងតែចំណុចទី៤ ស្ដីពីប្រាក់អាហារកិច្ចដែលត្រូវសម្រេចជាថ្មី ។

## ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្ដីចំពោះមុខលោកជា ពៅ ចំបាំងមុខ អ្នកស្រី មាន ទូម ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្ដឹងសាទុក្ខលើកទី២ លេខ២៦៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០២ របស់លោកមេធាវី ប៉ិច វិច្ឆិកា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៧៨(ង)ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែចំណុចទី៤ ដែលត្រូវទុកជាមោឃៈ និងសម្រេចជាថ្មីថា បង្គាប់ឱ្យលោកជា ពៅ បង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្ដាច់ឱ្យអ្នកស្រីមាន ទូច ចំនួន១២លាន រៀល(ដប់ពីលានគត់) ។ សំណូមពរ លើសពីនេះត្រូវលើកចោល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៩.០០០រៀល ដែលលោកជា ពៅ បានបង់គឺ :

- ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៤- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣ ។